

# ថ្នាំបង្ការជំងឺ COVID-19
# អ្វីដែលឪពុកម្ដាយត្រូវស្វែងយល់

## ថ្នាំបង្ការទាំងឡាយការពារប្រឆាំងនឹងការទទួលបានលទ្ធផលដ៏មិនល្អបំផុតដោយសារជំងឺ COVID-19។



- បើទោះបីជាជំងឺ COVID-19 ជាទូទៅមានកម្រិតស្រាលចំពោះកុមារក៏ដោយ ប៉ុន្តែកុមារដែលមានសុខភាពល្អក៏អាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ត្រូវចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬក៏ស្លាប់ដោយសារជំងឺ COVID-19 បានផងដែរ។ កុមារជាច្រើនក៏អាចកើតមានបញ្ហាផ្នែកសុខភាពផ្លូវចិត្ត និងផ្លូវកាយរយៈពេលវែងដោយសារការឆ្លងជំងឺ COVID-19 (ដែលហៅថាជំងឺ COVID រយៈពេលវែង) ផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 កាត់បន្ថយហានិភ័យនៃការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19។ ថ្នាំបង្ការក៏កាត់បន្ថយហានិភ័យនៃការកើតមានជំងឺ COVID រយៈពេលវែង ផងដែរ។
- ថ្នាំបង្ការជំងឺ COVID-19 ត្រូវបានធ្វើឱ្យថ្មីឡើងវិញ ដើម្បីការពារប្រឆាំងនឹងពូជមេរោគដែលកើតមានថ្មីៗនេះ។

**មានការណែនាំឱ្យកុមារទាំងអស់ដែលមានអាយុចាប់ពី 6 ខែឡើងទៅ ទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញសម្រាប់ឆ្នាំ 2023-2024 (updated 2023-2024 COVID-19 vaccine)។**



- **កុមារទាំងឡាយដែលមានអាយុចាប់ពី 6 ខែ ទៅ 4 ឆ្នាំ** គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna ដែលបានធ្វើឱ្យថ្មីឡើងវិញសម្រាប់ឆ្នាំ 2023-2024 យ៉ាងហោចណាស់ចំនួន 1 ដូស។ ពួកគេអាចនឹងត្រូវការទទួលចាក់ដូសបន្ថែមទៀត អាស្រ័យទៅលើចំនួនដូសថ្នាំបង្ការដែលពួកគេបានទទួលចាក់ពីពេលមុនមក។
- **កុមារទាំងឡាយដែលមានអាយុចាប់ពី 5 ឆ្នាំឡើងទៅ** គួរតែទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ប្រភេទ Pfizer ឬប្រភេទ Moderna ដែលបានធ្វើឱ្យថ្មីឡើងវិញសម្រាប់ឆ្នាំ 2023-2024 (updated 2023-2024 Pfizer or Moderna vaccine) ចំនួន 1 ដូស។
- **មនុស្សវ័យជំទង់ទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ** អាចទទួលចាក់ថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna ឬប្រភេទ Novavax បាន។ មនុស្សវ័យជំទង់ដែលបានទទួលចាក់ថ្នាំបង្ការពីពេលកន្លងមក ហើយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ និងចង់ទទួលចាក់ថ្នាំបង្ការប្រភេទ Novavax គួរតែទទួលចាក់ថ្នាំបង្ការប្រភេទ Novavax ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated Novavax vaccine) នេះចំនួន 1 ដូស។ យុវវ័យដែលមិនបានទទួលចាក់ថ្នាំបង្ការ ហើយដែលចង់ទទួលចាក់ថ្នាំបង្ការប្រភេទ Novavax គួរតែទទួលចាក់ថ្នាំបង្ការប្រភេទ Novavax ដែលបានធ្វើឱ្យថ្មីឡើងវិញនេះចំនួន 2 ដូស។
- កុមារទាំងឡាយដែល **ធ្លាប់មានជំងឺ COVID-19 រួចហើយនោះ** ក៏គួរតែទទួលចាក់ថ្នាំបង្ការផងដែរ។
- កុមារទាំងឡាយដែលមានប្រព័ន្ធភាពស៊ាំចុះខ្សោយកម្រិតមធ្យម ឬកម្រិតធ្ងន់ធ្ងរអាចនឹងត្រូវការទទួលចាក់ចាក់ថ្នាំបង្ការដូសបន្ថែមទៀត។
- ថ្នាំបង្ការជំងឺ COVID-19 អាចមានផ្ដល់ជូន **ក្នុងពេលតែមួយ** ជាមួយគ្នានឹងថ្នាំបង្ការជំងឺតាមទម្លាប់ផ្សេងទៀតបាន រួមមានទាំងថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំ (flu) ផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នក ឬចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

## របៀបទទួលចាក់ថ្នាំបង្ការ

- សូមចូលទៅកាន់គេហទំព័រ http://publichealth.lacounty.gov/vaccines/ ដើម្បីស្វែងរកទីតាំងមួយដែលនៅជិតអ្នក។ សូមប្រាកដថាទីតាំងទាំងនោះមានថ្នាំបង្ការដែលត្រឹមត្រូវសម្រាប់អាយុកូនរបស់អ្នក ហើយសូមសាកសួរអំពី **ការអនុញ្ញាតពីឪពុកម្ដាយ ឬអ្នកផ្ដល់ការថែទាំ (parent/caregiver consent)**។ ឱសថស្ថាន (កន្លែងលក់ថ្នាំពេទ្យ) ភាគច្រើនមិនអាចផ្ដល់ថ្នាំបង្ការជូនដល់កុមារដែលមានអាយុក្រោម 3 ឆ្នាំនោះទេ។
- សូមទូរស័ព្ទទៅកាន់មជ្ឈមណ្ឌលផ្ដល់ព័ត៌មានអំពីថ្នាំបង្ការ របស់នាយកដ្ឋានសុខភាពសាធារណៈ (DPH Vaccine Call Center) តាមរយៈលេខ **1-833-540-0473** ឬលេខ **2-1-1** ប្រសិនបើអ្នកត្រូវការជំនួយក្នុងការស្វែងរកថ្នាំបង្ការ ឬដើម្បីស្នើសុំការចាក់ថ្នាំបង្ការនៅតាមផ្ទះ។
- ថ្នាំបង្ការទាំងឡាយគឺមានការចេញថ្លៃចំណាយជូនដោយធានារ៉ាប់រង។ ប្រសិនបើកូនរបស់អ្នកមិនមានធានារ៉ាប់រង ឬមិនមានធានារ៉ាប់រងគ្រប់គ្រាន់ទេនោះ ពួកគេអាចទទួលចាក់ថ្នាំបង្ការបានដោយមិនគិតថ្លៃតាមរយៈកម្មវិធី Vaccine for Children។



County of Los Angeles Public Health

# ថ្នាំបង្ការជំងឺ COVID-19
# អ្វីដែលឪពុកម្តាយត្រូវស្វែងយល់



## ផលប៉ះពាល់ផ្សេងៗរបស់ថ្នាំបង្ការ

- កូនរបស់អ្នកអាចនឹងមានផលប៉ះពាល់ដែលប្រហាក់ប្រហែលគ្នាទៅនឹងផលប៉ះពាល់នៃការចាក់ថ្នាំបង្ការជំងឺតាមទម្លាប់សម្រាប់ពេលកុមារភាពផ្សេងទៀតផងដែរ។ ជាធម្មតា ផលប៉ះពាល់ទាំងឡាយ **មានកម្រិតស្រាល ហើយនឹងបាត់ទៅវិញ** ក្នុងអំឡុងពេលពីរឬបីថ្ងៃក្រោយ។ កុមារមួយចំនួនមិនកើតមានផលប៉ះពាល់ទេ។
- ផលប៉ះពាល់ទូទៅរួមមានដូចជា ការឈឺ ឡើងហើម ឬឡើងក្រហមនៅនឹងដៃ ឬភ្លៅ នៅត្រង់កន្លែងដែលបានចាក់ថ្នាំបង្ការនោះ ឈឺសាច់ដុំឬឈឺតាមសន្លាក់ ហើមកូនកណ្តុរ គ្រុនក្តៅ គ្រុនរងា ឈឺក្បាល ឆាប់ខឹងឬឆាប់យំ មានអារម្មណ៍អស់កម្លាំង ងងុយគេង និងបាត់បង់ចំណង់អាហារ ជាដើម។

បរិមាណដូសនៃថ្នាំបង្ការជំងឺ COVID-19 គឺផ្អែកទៅលើអាយុរបស់កុមារ ហើយមិនមែនផ្អែកទៅលើមាឌ ឬទម្ងន់របស់ពួកគេនោះទេ។ កុមារទាំងឡាយដែលមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ទទួលចាក់កម្រិតដូសថ្នាំបង្ការដែលដូចគ្នាទៅនឹងដូសសម្រាប់មនុស្សពេញវ័យ ផងដែរ។




## សុវត្ថិភាពទាក់ទងទៅនឹងថ្នាំបង្ការ



- **ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយគឺមានសុវត្ថិភាពសម្រាប់កុមារ។** មុនពេលធ្វើការណែនាំថ្នាំបង្ការជំងឺ COVID-19 សម្រាប់កុមារនោះ មានការធ្វើតេស្តសាកល្បងផ្នែកព្យាបាលជំងឺ (clinical trials) ចំពោះកុមាររាប់ពាន់នាក់ ដើម្បីស្វែងយល់អំពីសុវត្ថិភាពរបស់ថ្នាំបង្ការទាំងឡាយ និងថាតើថ្នាំបង្ការទាំងនេះដំណើរការបានល្អកម្រិតណា។ ចាប់តាំងពីពេលនោះមក កុមាររាប់សិបលាននាក់នៅក្នុងសហរដ្ឋអាមេរិកបានទទួលចាក់ថ្នាំបង្ការ។
- ថ្នាំបង្ការជំងឺ COVID-19 ទាំងឡាយបានឆ្លងកាត់ — និងនៅតែបន្តឆ្លងកាត់ — **ការត្រួតពិនិត្យផ្នែកសុវត្ថិភាពយ៉ាងយកចិត្តទុកដាក់** បំផុតក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិក។
- មានការរាយការណ៍ថាមានករណីនៃបញ្ហា myocarditis (ការរលាកសាច់ដុំបេះដូង) និងបញ្ហា pericarditis (ការរលាកស្រទាប់ខាងក្រៅនៃបេះដូង) ដែលកម្រនឹងកើតមាននោះ ចំពោះកុមារបន្ទាប់ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 រួច ដែលភាគច្រើនមានការរាយការណ៍ថាកើតមានចំពោះមនុស្សភេទប្រុសទាំងឡាយដែលមានអាយុចាប់ពី 12 ទៅ 39 ឆ្នាំ។ ហានិភ័យនៃការកើតមានចំណុចនេះបន្ទាប់ពីការចាក់ថ្នាំបង្ការគឺកម្រណាស់។
- កូនរបស់អ្នក **មិនអាចកើតជំងឺ COVID-19** ពីការចាក់ថ្នាំបង្ការជំងឺ COVID-19 នោះទេ។
- មិនមានភស្តុតាងណាមួយដែលបង្ហាញថា ថ្នាំបង្ការជំងឺ COVID-19 ទាំង ឡាយប៉ះពាល់ដល់ការលូតលាស់ ឬការមានបញ្ហាមិនមានកូននោះទេ។



សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមចូលទៅកាន់គេហទំព័រ cdc.gov/coronavirus/vaccine។

VaccinateLACounty.com

County of Los Angeles Public Health